**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខ:១៩០
ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៤
<u>សាលដីកា</u>
លេខ:២៥៨
ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម **ខិត មុន្នី** ជាប្រធាន
២-លោក **ជីវ កេង** ជាចៅក្រមរបាយការណ៍
៣-លោក **យស់ សូខឿន** ជាចៅក្រម
៤-លោក **ប៉ែន សាវឿន** ជាចៅក្រម
៥-លោក **យូរ ឧត្តរា** ជាចៅក្រម

<u>ក្រឡាបញ្ជី</u>

-លោក **ស៊ិន ភារៈ**

<u>តំណាងមហាអយ្យការ</u>

-លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៣(ឈ) ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណី លេខ៣៧៨ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ ខៀវ ស៊ីណា (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥២ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ៥៨ ផ្លូវលេខ២៤២ សង្កាត់ចតុមុខ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មានលោកជា សារ៉ាត់ ជាតំណាង និងលោកមេធាវី ផាត់ ពៅស៊ាង ។

ចុងចម្លើយឈ្មោះ FRAÇOISE LAVELLE (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤២ឆ្នាំ មុខរបរ ស្ថាបត្យករ ទីលំនៅផ្ទះលេខ១៣៤A ផ្លូវប៉ាស្ទ័រ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

មានមេធាវីលោក អ៊ុក ភូរិ ជាតំណាង ។

**<u>កម្មវត្ថុបណ្តឹង:</u>** ប្តឹងសុំមោឃភាពកិច្ចសន្យាសាងសង់ចុះថ្ងៃទី២៨- ០៦-២០០២

**<u>បណ្តឹងតបៈ</u>**ប្តឹងទារប្រាក់ថ្លៃសេវាចំនួន២២.២៧៦.៨០ដុល្លាអាមេរិក

បានឃើញបណ្តឹងសាទុក្ខលេខ ១២១ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៤ របស់លោក អ៊ុក ភូរិ មេធាវីការពារឱ្យចុងចម្លើយ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ០៣(ឈ) ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១៩០ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះអ្នកស្រី ខៀវ ស៊ីណា ចុះថ្ងៃទី ១០-៧-២០០២ ថាខ្លួនប្តឹងសុំមោឃៈភាពកិច្ចសន្យាគ្រប់គ្រងដំណើរការសាងសង់សណ្ឋាគារស្ទឹងសៀមរាប ចុះថ្ងៃទី២៨-៦-២០០២ ដោយអាងហេតុថា កន្លងមកខ្លួនបានចុះកិច្ចសន្យាដោយមានការពន្យល់បំភាន់មួយជាមួយជនជាតិបារាំងម្នាក់ឈ្មោះ LAVELLE ដោយគាត់ជាតំណាងឱ្យក្រុមហ៊ុន LBL ក្រោយពីខ្លួនបានចុះហត្ថលេខាហើយ ខ្លួនបានសួរទៅប្រធានក្រុមហ៊ុន LBL ពេលនោះប្រធានក្រុមហ៊ុនប្រាប់ថាគាត់បានប្រើអ្នកស្រី LAVELLE ឱ្យយកប្លង់មកឱ្យខ្លួនមើល តែមិនឱ្យយកកិច្ចសន្យាគ្រប់គ្រងដំណើរសាងសង់ តម្លៃសាងសង់ ៧០០.០០០ដុល្លា និងតម្លៃប្លង់ ២២.២៧៦.៨០ដុល្លា មកឲ្យចុះហត្ថលេខានោះទេ ។ ពីព្រោះគាត់មិនបានយល់ព្រមក្នុងតម្លៃ ៧០០.០០០ដុល្លានោះឡើយ ។ ម៉្យាងទៀតបញ្ហាចុះហត្ថលេខាលើកិច្ចសន្យាបLAVELLE ក៏មិនបានប្រាប់ខ្លួនដែរ ។ ខ្លួនសូមជំរាបលោកប្រធានតុលាការថា កិច្ចសន្យាជាភាសាបារាំង ខ្លួនមិនចេះភាសាបារាំងទេ តែ LAVELLE បាននិយាយឱ្យខ្លួនទុកចិត្តគាត់ ពេលខ្លួនសួរទៅគាត់ គាត់ឆ្លើយថាសជានិច្ចហើយគាត់បានបង្ហាញនូវតម្លៃសាងសង់ ៧០០,០០០ដុល្លា និង តម្លៃប្លង់ ២២,២៧៦,៨០ ដុល្លាក្នុងកិច្ចសន្យាគ្រប់គ្រងដំណើរការសាង-សង់ធ្វើឱ្យខ្លួនជឿជាក់លើគាត់ហើយគាត់តឿនឱ្យខ្លួនចុះហត្ថលេខាយ៉ាងប្រញាប់មុនពេលខ្លួនចេញដំណើរទៅបរទេស ថ្ងៃនោះតែម្តង ។ ដូចនេះ LAVELLE មកបោកប្រាស់ ខ្លួនឱ្យចុះហត្ថលេខានៅលើកិច្ចសន្យាគ្រប់គ្រងដំណើរការសាងសង់ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១១(គ) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ១០-៧-២០០២ របស់ដើមចោទ និងជាចុងបណ្តឹងតប ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ០៩-៩-២០០២ និងសំណូមពរជម្ងឺចិត្តរបស់លោក នុត ទីតូ មេធាវីការពារក្តីឱ្យចុងចម្លើយ និងជាដើមបណ្តឹងតប ទុកជាត្រឹមត្រូវតាមទម្រង់ច្បាច់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

៣-ទុកជាមោឃៈនូវកិច្ចសន្យាគ្រប់គ្រងដំណើរការសាងសង់ ចុះថ្ងៃទី២៨-៦-២០០២ រវាងលោកជំទាវទៀវ ស៊ីណា និងកញ្ញា FRANÇIOSE LAVELLE ចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ តាមមាត្រា ៧ នៃក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

៤-បដិសេធសំណួមពរជំងឺចិត្តរបស់ដើមចោទ និងជាចុងបណ្តឹងតប

៥-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៧.០០០រៀល ដែលដើមចោទ និងជាចុងបណ្តឹងតប បង់ជួសចុងចម្លើយ និង ជាដើមបណ្តឹងតប បានបង់ទុកជាស្រេច កាលបើហួសបណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយ និងជាដើមបណ្តឹងតប សងប្រាក់ ៧.០០០រៀល ទៅដើមចោទ និងជាចុងបណ្តឹងតបវិញ តាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ។

៦-បង្គាប់ឱ្យដើមចោទ និងជាចុងបណ្តឹងតប បង់ប្រាក់ប្រដាប់ក្តីចំនួន ៧.០០០៛ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹង ១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់សាក្សី២.០០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៣.០០០៛ សរុប៧.០០០៛ ប្រាក់នេះកាត់ពីប្រាក់៧.០០០៛ ដែលដើមចោទ និងជាចុងបណ្តឹងតប បានបង់ទុកជាស្រេច ។

-កាលបើហួសបណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយ និងជាដើមបណ្តឹងតបសងប្រាក់ ៧.០០០៛ ទៅដើមចោទ និងជាចុងបណ្តឹងតបវិញ តាមច្បាប់ ស្តីពីប្រាក់ប្រដាប់ក្តី ។

៧-សាលក្រមនេះ ជំនុំជំរះជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍ រយៈពេលពីរខែ គិតចាប់ពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៤(គ) ចុះថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៣ របស់លោក មេធាវី ផាត់ ពៅស៊ាង ការពារឱ្យដើមចោទ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១១(គ) ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០០៣ របស់តុលាការក្រុងភ្នំពេញត្រង់ចំណុច វិនិច្ឆ័យសេចក្តីត្រង់ចំណុច ទី៤ (សំណួមពរជំងឺចិត្ត) ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ០៣(ឈ) ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៣-០៤-២០០៣ របស់ឈ្មោះ FRANÇOISE LAVIELLE ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៤-៤-២០០៣ របស់លោកមេធាវី ផាត់ ពៅស៊ាង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់និងគតិច្បាប់ ។

៣-កម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១១(គ) ចុះថ្ងៃទី ២៥-០២-២០០៣ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៤-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹងចំនួន២៥៥០៛ ។ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០៛ ចំណាយក្នុងការប្រគល់ដីកាកោះ៥.០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ ។

៥-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៧-០១-២០០៤ ចំពោះមុខ មេធាវីតំណាងដើមចោទនិងចុងចម្លើយនិងប្រកាសជាសាធារណៈនៅថ្ងៃទី០៦-០២-២០០៨ ចំពោះមេធាវីតំណាងដើមចោទ និងចុងចម្លើយ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១២១ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៤ របស់លោកអ៊ុក ភូរិ មេធាវីការពារឱ្យចុងចម្លើយ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ០៣(ឈ) ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ .

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអេយ្យការថាៈ
សាលដីការដ្ឋប្បវេណីលេខ០៣(ឈ)ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេច ។

-បានស្តាប់ចម្លើយរបស់ឈ្មោះជា សារ៉ាត តំណាងឱ្យអ្នកស្រីទៀវ ស៊ីណា នាពេលសវនាការថា : កាលដើមឡើយ ខ្លួនមានទំនាក់ទំនងជាមួយក្រុមហ៊ុន BL ដើម្បីសាងសង់សណ្ឋាគារខេត្តសៀមរាប ។ ពេលសាងសង់សណ្ឋាគារ ខ្លួនមានវត្តមាននៅទីនោះដែរ ហើយខ្លួនក៏មិនបានមើលកិច្ចសន្យាដែរ ។ ក្នុងការទំនាក់ទំនងជាមួយក្រុមហ៊ុន BL បានពិភាក្សាតម្លៃសាងសង់ ៧៨ ម៉ឺនដុល្លា បងស្រីខ្លួនសុំ ៧០ម៉ឺនដុល្លាអាមេរិក ។ តម្លៃ៧០ម៉ឺន បងស្រីខ្លួនគាត់ក៏យល់ព្រមចុះកិច្ចសន្យា ។ ក្រោយពេលចុះកិច្ចសន្យាបានជាងដប់ថ្ងៃ ទើបដឹងថា បានចុះកិច្ចសន្យាច្រឡំ ទើបបងស្រីរបស់ខ្លួន ក៏បានប្តឹងសុំមោឃភាពកិច្ចសន្យានេះ ខ្លួនមិនបានយកអ្នកស្រី FRANÇIOSE LAVELE គូរប្លង់ទេ ហើយក៏មិនបានយកប្លង់អ្នកស្រី FRANÇIOSE LAVELE មកប្រើប្រាស់ដែរ ។ ខ្លួនសូមតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកផាត់ ពៅស៊ាង ជាមេធាវីការពារឱ្យដើមចោទបានលើកឡើងថាៈ ចំពោះកិច្ចសន្យា របស់អ្នកស្រីខៀវ ស៊ីណា និងកញ្ញា FRANÇIOSE LAVELE សរសេរជាភាសាបារាំង កូនក្តីខ្លួនមិនចេះភាសាបារាំង ឃើញកិច្ចសន្យាតម្លៃ ៧០ម៉ឺនដុល្លា ក៏ចុះកិច្ចសន្យាទៅ ។ កូនក្តីខ្លួនគាត់ចុះកិច្ចសន្យាភ័ន្តច្រឡំ ក្រោយពេលដែលចុះកិច្ចសន្យាបាន១៤ថ្ងៃ ហើយទើបគាត់ដឹងថាខ្លួនចុះកិច្ចសន្យាភ័ន្តច្រឡំទេ ។ កូនក្តីខ្លួនគាត់ក៏បានប្តឹងមោឃភាពកិច្ចសន្យា

នេះទៅ ។ កូនក្តីខ្លួនមិនបានយកប្លង់អ្នកស្រី FRANÇIOSE LAVELE មកប្រើប្រាស់ទេ ហើយកូនក្តីខ្លួនបានប្រគល់ឲ្យអ្នកស្រី FRANÇIOSE LAVELE វិញ ។

ចំណុចមួយជាចំណុចសំខាន់ទៅលើតម្លៃ៧០ ម៉ឺនដុល្លាអាមេរិក ជាគុពិតក្រុមហ៊ុន BL មិនព្រមសាងសង់ទេ ។ ខ្លួនសុំតម្កល់សាលដីកាសាលាឧទ្ធរណ៍លេខ ៣(ឈ) ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០០៤ ទុកជាបានការទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយតំណាងដើមចោទ និងសេចក្តីសន្និដ្ឋានការពារ របស់មេធាវីដើមចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១២១ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៤ របស់លោកអ៊ុក ភូរិ ជាមេធាវីចុងចម្លើយ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់អាចឱ្យតុលាការជឿបានថា កិច្ចសន្យាចុះថ្ងៃទី ២៨-៦-២០០២ ពិតជាមានការក័ន្តច្រឡំមែន ពីព្រោះថា:

- ដើមចោទពុំដែលបានពឹងពាក់ពីមុនដើម្បីឱ្យកញ្ញា FRANOISE LAVELLE ឱ្យគូរប្លង់ឱ្យទេ ។

-ក្រោយពីចុះកិច្ចសន្យាបានដាងដប់ថ្ងៃដើមចោទក៏ប្តឹងសុំមោឃៈភាពកិច្ចសន្យានេះភ្លាមដែរ ម៉្យាង-ទៀតដើមចោទ ក៏មិនបានប្រើប្លង់ដែលគូរដោយកញ្ញា FRANÇIOSE LAVELE ដើម្បីសាងសង់សណ្ឋាគារដែរ ។

ដូច្នេះដើមចោទ មានសិទ្ធិប្តឹងសុំមោឃភាពកិច្ចសន្យាចុះថ្ងៃទី២៦-៨-២០០២ តាមមាត្រា៧-៨ និង១៩ នៃក្រឹត្យច្បាប់លេខ ៣៨ក្រច ចុះថ្ងៃទី ២៨-១០-១៩៨៨ ។

-យល់ឃើញថា ចុងចម្លើយពុំបានធ្វើសរណាជូនមកតុលាការកំពូលទេ ហើយពុំបានមកចូលរួមសវនាការនេះដែរ ដោយបានសុំពន្យាពេលសវនាការទៅថ្ងៃក្រោយ ។ ការសុំពន្យាពេលនេះ ពុំមានមូលហេតុត្រឹមត្រូវទេ ដើម្បីកុំឱ្យអូសបន្លាយពេលវេលា គប្បីជំនុំជំរះក៏បាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ០៣(ឈ) ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**ទនិច្ឆ័យសេចក្តីចំពោះមុខតំណាងដើមមាន កំបាំងមុខចុងចម្លើយ**

**ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ១២១ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៤ របស់លោកអ៊ុក កូរិ ជាមេធាវីចុងចម្លើយទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ០៣(ឈ) ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលដើមចោទ បានបង់គឺ ៖

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្មឺងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០រៀល ហើយតម្រូវឱ្យចុងចម្លើយសងប្រាក់ ១៩.០០០៛ នេះទៅដើមចោទវិញ ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៤ ។